# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលាខេត្តពោធិ៍សាត់
លេខ.............ខពស

## សេចក្តីប្រកាសជ្រើសរើសបុគ្គលិក

ផែនការអនុវត្តដំណាក់កាលទី១ (២០១១-២០១៤) ផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹង និងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុក ឱ្យក្លាយជា ស្ថាប័នអភិបាលកិច្ចមូលដ្ឋាន និងអភិវឌ្ឍមូលដ្ឋានយ៉ាងពិតប្រាកដ។ មូលដ្ឋានគ្រឹះសំខាន់ៗ ដូចជារចនាសម្ព័ន្ធ នីតិវិធី ប្រព័ន្ធ និងឧបករណ៍ជាច្រើនសម្រាប់ការបំពេញការងារ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំឡើងវិញ និងបានផ្តល់ជាបង្អែកយ៉ាងរឹងមាំសម្រាប់ការបោះជំហានឆ្ពោះទៅមុខ។ ទាំងនេះបណ្តាលឲ្យផអ៣ទី១ ក្លាយជាកម្លាំងចលករមួយដ៏សំខាន់សម្រាប់ការងារកំណែទម្រង់ និងជាសនិទានកម្មដ៏សំខាន់ ដែលនាំឲ្យរាជរដ្ឋាភិបាល តាមរយៈកិច្ចប្រជុំលើកទី១០ របស់ គ.ជ.អ.ប កាលពីខែធ្នូ ឆ្នាំ២០១៤ បានសម្រេចចិត្តអនុវត្តដំណាក់កាលទី២ (ផអ៣ទី២) ដែលចាប់ផ្តើមពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៧។

អាស្រ័យហេតុនេះ ក្នុងក្របខ័ណ្ឌ ផអ៣ **សាលាខេត្តពោធិ៍សាត់** សូមប្រកាសជ្រើសរើស បេក្ខជន សម្រាប់មុខតំណែងដូចខាងក្រោម៖

| មុខតំណែង | ចំនួន | ទីកន្លែងបំពេញការងារ | ប្រាក់កម្រៃ |
|---|---|---|---|
| បុគ្គលិកគាំទ្របច្ចេកទេស ក្រុង ស្រុក | ០៦រូប | -ស្រុកក្រគរ (០១រូប)<br>-ស្រុកបាកាន (០១រូប)<br>-ស្រុកកណ្តៀង (០១រូប)<br>-ស្រុកភ្នំក្រវាញ (០១រូប)<br>-ស្រុកវាលវែង (០១រូប)<br>-ក្រុងពោធិ៍សាត់ (០១រូប) | ២៥០ដុល្លា/១ខែ |

តួនាទី និងភារកិច្ចទទួលខុសត្រូវលម្អិត (TOR) និងតម្រូវការគុណសម្បត្តិសម្រាប់មុខតំណែងខាងលើ ព្រមទាំងពាក្យសុំបម្រើការងាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប អាចរកបាននៅសាលារាជធានី ខេត្ត ក្រុង ស្រុកសាមីនីមួយៗ និងមាននៅលើគេហទំព័ររបស់ គ.ជ.អ.ប(http://www.ncdd.gov.kh/procurementjobs) និងមានបិទផ្សាយនៅលើក្តារព័ត៌មានសាលា ខេត្ត ក្រុង ស្រុក អង្គការសង្គមស៊ីវិល និងមន្ទីរ ពាក់ព័ន្ធនានាជុំវិញ ខេត្ត រួមទាំងសាលាឃុំ សង្កាត់ផងដែរ។

បេក្ខជន បេក្ខនារីដែលមានចំណាប់អារម្មណ៍ សូមផ្ញើលិខិតដាក់ពាក្យសុំ និងប្រវត្តិរូបសង្ខេប (រាប់បញ្ចូលទាំងពាក្យសុំបម្រើការងាររបស់ គ.ជ.អ.ប) ដោយមានបញ្ជាក់ព័ត៌មានសម្រាប់ទំនាក់ទំនង (រួមមាន៖ អាសយដ្ឋាន លេខទូរស័ព្ទ ឬអ៊ីម៉ែល) មកកាន់ផ្នែកគ្រប់គ្រងបុគ្គលិកនៃទីចាត់ការគ្រប់គ្រងធនធានមនុស្សរបស់សាលាខេត្ត 012 918 251 នៅគ្រប់ម៉ោងធ្វើការ ឬតាមរយៈសារអេឡិចត្រូនិច (អ៊ីម៉ែល) pichsovann17@yahoo.com ។

**ស្ត្រីត្រូវបានលើកទឹកចិត្តក្នុងការដាក់ពាក្យសម្រាប់មុខតំណែងនេះ**

**ថ្ងៃឈប់ទទួលពាក្យៈ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥។**

**មានតែបេក្ខជនដែលមានឈ្មោះក្នុងបញ្ជីសម្រាំងបេក្ខជនអាទិភាព (shortlist) ប៉ុណ្ណោះ**
**ដែលនឹងទទួលបានព័ត៌មានអំពីការប្រឡងជ្រើសរើស។**

បញ្ជាក់៖ មុខតំណែងនេះជាប្រភេទកិច្ចសន្យា (**ក្នុងក្របខ័ណ្ឌ ផអ៣**) ដូច្នេះបេក្ខជនដែលនឹងត្រូវជ្រើសរើសឱ្យបំពេញការងារ ត្រូវតែមិនមែនជាមន្ត្រីរាជការស៊ីវិល។ ក្នុងករណីដែលបេក្ខជនជាមន្ត្រីរាជការស៊ីវិល បេក្ខជននោះត្រូវដាក់ពាក្យសុំស្ថិតនៅក្នុងភាពទំនេរគ្មានប្រាក់បៀវត្ស ក្នុងរយៈពេលនៃការបំពេញការងារជាមួយកម្មវិធីជាតិ។

ពោធិ៍សាត់ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០១៥
**សាលាខេត្តពោធិ៍សាត់**

**ចម្លងជូន**
-សាលាក្រុង ស្រុក
-មន្ទីរ អង្គភាពនានាជុំវិញសាលាខេត្ត
-មន្ទីរព័ត៌មានខេត្ត
(ដើម្បីផ្សព្វផ្សាយ)
-ឯកសារ-កាលប្បវត្តិ